# ព្រឹត្តិការណ៍អ៊ីនធឺណិតបើកទូលាយ ២០១៩

វត្តមានរបស់ស្មាតហ្វូន និងបច្ចេកវិទ្យាព័ត៌មានវិទ្យាបានធ្វើអោយបណ្តាញសង្គមក្លាយជាមធ្យោបាយទំនាក់ទំនងមួយយ៉ាងសំខាន់ និងឆាប់រហ័ស ។ ក៏ប៉ុន្តែភាពរីកលូតលាស់នៃការប្រើប្រាស់បណ្តាញសង្គមក៏បាននាំមកនូវហានិភ័យមួយចំនួនដូចជា ព័ត៌មានក្លែងក្លាយ ការប្រើពាក្យសម្តីប្រមាថមើលងាយ ការយាយីផ្នែកផ្លូវភេទនៅតាមប្រព័ន្ធអ៊ីនធឺណិត និង បញ្ហាផ្សេងៗទៀត ។ ដើម្បីចូលរួមលើកកំពស់សុវត្ថិភាព និង ការប្រើប្រាស់បណ្តាញសង្គមប្រកបដោយក្រមសីលធម៌ និងសេចក្តីថ្លៃថ្នូរ ក្រុមការងារលើកកម្ពស់សិទ្ធិឌីជីថល នឹងរៀបចំព្រឹត្តិការណ៍អ៊ីនធឺណិតបើកទូលាយ ២០១៩ នៅថ្ងៃ ១៧ ខែមីនា ឆ្នាំ២០១៩ នៅភោជនីយដ្ឋានទន្លេបាសាក់ ២ ចាប់ពីម៉ោង ៧:៣០ព្រឹក ដល់ម៉ោង ១២ ថ្ងៃត្រង់។ ព្រឹត្តិការណ៍អ៊ីនធឺណិតបើកទូលាយ២០១៩ គឺជាវេទិកាសាធារណៈសម្រាប់មហាជនទូទៅ ។ វេទិកានេះនឹងផ្តល់ឱកាសអ្នកប្រើប្រាស់បណ្តាញសង្គម សិស្សានុសិស្ស យុវជន អ្នកការពារសិទ្ធិមនុស្ស អ្នកស្រាវជ្រាវកិច្ចការសង្គម អ្នកសារព័ត៌មាន និងបុគ្គលិកអង្គការសង្គមស៊ីវិលបានជួបប្រាស្រ័យទាក់ទងនិងផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ដើម្បីចូលរួមចំណែកធ្វើអោយការប្រើប្រាស់ បណ្តាញសង្គមកាន់តែមានសុវត្ថិភាព ប្រកបដោយសេចក្តីថ្លៃថ្នូរ និងការទទួលខុសត្រូវខ្ពស់ ។

កម្មវិធី ៖ ព្រឹត្តិការណ៍អ៊ីនធឺណិតបើកទូលាយ ២០១៩ (Open Cyber Talk 2019)

ទីកន្លែង ៖ ភោជនីយដ្ឋានទន្លេបាសាក់ ២

កាលបរិច្ឆេទ ៖ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០១៩ ចាប់ពីម៉ោង ៧:៣០ ព្រឹកដល់ ១២ ថ្ងៃត្រង់

អ្នកចូលរួម ៖ មហាជនទូទៅដែលបានចុះឈ្មោះចូលរួមតាមរយៈ

https://goo.gl/forms/FZALsJfEbC5Myasu2

***សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់លេខ៖**

1- លោក ស ម៉ូរី 016 930 588
2- អ្នកនាង ហុក ណារិន 017 57 96 96
3- លោក យឿង សុធារ៉ា 070 400 131